# Monthly Report Volume 42

June 2025

## Project Activities in June:

- 3rd : Monthly Meeting with JICA HQ / Cambodia Office
- 9th : Kick-off Meeting with PTMT members in BTB
- 10th–13th : TOT3 Demonstrations in BTB
- 23rd : Kick-off Meeting with PTMT members in KC
- 24th–27th : TOT3 Demonstrations in KC
- 30th Jun.- 7th Jul. : Conducting Online Post Training Evaluation

## Establishment and Kick-off of Provincial Training Management Team (PTMT) in BTB and KC

On 17 June, the Provincial Training Management Team (PTMT) were officially established in the pilot provinces. A total of 15 members in Kampong Cham Province (KC) and 9 members in Battambang Province (BTB) were nominated by the Ministry of Health (MOH), with representatives from the Provincial Health Department (PHD), Regional Training Center (RTC), Provincial Referral Hospital (PRH), and Operational District (OD).

Following a series of discussions and coordination among HRDD, the National TMT, and the Project, the Terms of Reference (TOR) for the PTMT was finalized. The primary role of the P-TMT is to establish and implement a sustainable and effective framework that supports the planning, execution, monitoring, and continuous improvement of In-service Training (INSET) for nurses in the pilot provinces. Their responsibilities also include the overall management of INSET operations — ranging from course design and logistical coordination to facilitation and evaluation — in close collaboration with the National TMT.

Kick-off meetings for the PTMT were held on 9 June in BTB and on 23 June in KC to discuss the INSET implementation framework. Both provinces are scheduled to conduct eight INSET courses targeting nurses working at the PHD, RTC, PRH, OD, Referral Hospital (RH), and Health Center (HC). The PTMT, in collaboration with the Project, are currently finalizing the detailed implementation plans, which will be presented at the 6th Joint Coordination Committee (JCC) meeting scheduled for 16 July.



Meeting with KC PTMT



Meeting with BTB PTMT

## Implementation of TOT3 Demonstrations for Future INSET Trainers

The 3rd round of Training of Trainers (TOT3) for future INSET trainers in BTB and KC was successfully completed in May 2025. Following the TOT3, demonstration sessions were organized in BTB from 10 to 13 June and in KC from 24 to 27 June.

During the demonstration sessions, each participant was assigned one lesson in each course and delivered a lecture in front of senior trainers. These senior trainers observed the sessions and evaluated the trainees' performance using the Assessment Sheet jointly developed by the Project and the National TMT. Trainers were assessed on aspects such as lesson planning, communication skills, use of teaching materials, and facilitation techniques. Constructive feedback was provided individually to support continuous improvement of their teaching skills.

The demonstration sessions not only served as an opportunity to assess trainers' readiness but also contributed to fostering mutual learning among trainers. Based on the evaluation results, qualified trainers will be officially assigned as provincial trainers and expected to take a leading role in the upcoming INSET implementation in both provinces.

The Project would like to express its sincere appreciation to all key actors involved — particularly HRDD, TMT, senior trainers, PHD, RTC, and PRH — for their invaluable guidance and strong collaboration throughout the process. A comprehensive report summarizing the implementation process and outcomes of TOT3 will be submitted to the Minister of Health and presented at the 6th JCC meeting.







Demo Sessions in BTB&KC

## UPCOMING ACTIVITIES IN JULY

- 30th Jun.-7th Jul.: Conducting Online Post Training Evaluation
- 7th : Monthly Meeting with JICA HQ / Cambodia Office
- 16th: 6th JCC meeting

## CONTACT INFORMATION

Scan here to find out more about us:

JICA's FB Page

Project's Homepage

**Email**: info@jicastrings.com

**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2,
Tuol Kork District, Phnom Penh

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh

# Monthly Report Volume 42

មិថុនា ២០២៥

## សកម្មភាពគម្រោងប្រចាំខែមិថុនា៖

- ថ្ងៃទី៣៖ ការប្រជុំប្រចាំខែជាមួយ ការិយាល័យកណ្ដាល JICA និង ការិយាល័យ JICA នៅប្រទេសកម្ពុជា
- ថ្ងៃទី៩៖ កិច្ចប្រជុំជាមួយក្រុមការងារគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់ខេត្តបាត់ដំបង
- ថ្ងៃទី១០ ដល់ទី១៣ ៖ វគ្គបណ្ដុះបណ្ដាលសាកល្បង គ្រូបង្គោលវគ្គ៣ (ខេត្តបាត់ដំបង)
- ថ្ងៃទី៩៖ កិច្ចប្រជុំជាមួយក្រុមការងារគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់ខេត្តកំពង់ចាម
- ថ្ងៃទី២៤ ដល់ទី២៧៖ វគ្គបណ្ដុះបណ្ដាលសាកល្បង គ្រូបង្គោល៣(ខេត្តកំពង់ចាម)
- ថ្ងៃទី៣០ ខែមិថុនា ដល់ទី៧ ខែកក្កដា៖ អនុវត្តន៍ការវាយតម្លៃក្រោយការបណ្ដុះ បណ្ដាលតាមអ៊ីនធឺណិត

## ការតែងតាំង និងការចាប់ផ្ដើមនៃ ក្រុមការងារគ្រប់គ្រងបណ្ដុះបណ្ដាលថ្នាក់ខេត្ត (PTMT) នៅ ខេត្តកំពង់ចាម និង ខេត្តបាត់ដំបង

នៅថ្ងៃទី១៧ ខែមិថុនា ក្រុមការងារគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់ខេត្ត (PTMT) ត្រូវបាន តែងតាំងជាផ្លូវការដោយក្រសួងសុខាភិបាល (MOH) សម្រាប់ខេត្តសាកល្បងទាំងពីរដែលមានសមាជិកសរុបចំនួន២៤នាក់ ក្នុងនោះ មាន១៥នាក់មកពីខេត្តកំពង់ចាម និងសមាជិកចំនួន៩នាក់ទៀតមកពីខេត្តបាត់ដំបង។ ក្រុមការងារនេះមានតំណាងមកពីមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត (PHD) សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ (RTC) មន្ទីរពេទ្យបង្អែកខេត្ត (PRH) និងស្រុកប្រតិបត្តិ (OD) នៃខេត្តទាំងពីរ។

បន្ទាប់ពីមានការពិភាក្សា និងការសម្របសម្រួលជាបន្តបន្ទាប់ពីនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស (HRDD) និងក្រុមការងារគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់ជាតិ (TMT) និងគម្រោង លក្ខខណ្ឌនៃតួនាទីភារកិច្ច (TOR) សម្រាប់ PTMT ត្រូវបានបញ្ចប់។ តួនាទីចម្បងរបស់ P-TMT គឺបង្កើត និងអនុវត្តន៍ប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព ដែលគាំទ្រដល់ការរៀបចំផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងការកែលម្អជាបន្តបន្ទាប់នៃការបណ្ដុះបណ្ដាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) នៅក្នុងខេត្តសាកល្បង។ ទំនួលខុសត្រូវរបស់ក្រុមការងារ PTMT ក៏រួមបញ្ចូលផងដែរ នូវការគ្រប់គ្រងរួមនៃប្រតិបត្តិការ INSET ចាប់ពីការរៀបចំវគ្គសិក្សា និងការសម្របសម្រួលទីកន្លែង រហូតដល់ការរៀបចំផ្សេងៗ និងការវាយតម្លៃដោយសហការយ៉ាងជិតស្និទ្ធជាមួយ TMT ថ្នាក់ជាតិ។

កិច្ចប្រជុំចាប់ផ្ដើមសម្រាប់ PTMT ត្រូវបានធ្វើឡើងនៅថ្ងៃទី៩ ខែមិថុនា នៅខេត្ត BTB និងនៅថ្ងៃទី២៣ ខែមិថុនា នៅខេត្ត KC ដើម្បីពិភាក្សាអំពីក្របខ័ណ្ឌការអនុវត្ត INSET។ ខេត្តទាំងពីរគ្រោងនឹងបើកវគ្គបណ្ដុះបណ្ដាល INSET ចំនួនប្រាំបីម៉ូឌុល ដោយផ្ដោតលើគិលានុបដ្ឋាកដែលធ្វើការនៅ PHD, RTC, PRH, OD, មន្ទីរពេទ្យបង្អែក (RH) និងមណ្ឌលសុខភាព (HC)។ បច្ចុប្បន្ននេះក្រុមការងារ PTMT ដោយសហការជាមួយគម្រោងបាន និងកំពុងបញ្ចប់ការធ្វើផែនការអនុវត្តលម្អិតដែលនឹងត្រូវបង្ហាញនៅក្នុងកិច្ចប្រជុំគណៈកម្មការសម្របសម្រួលគម្រោងពង្រឹងប្រព័ន្ធបណ្ដុះបណ្ដាលក្នុងពេលបម្រើការងារលើកទី៦ ដែលគ្រោងនឹងធ្វើនៅថ្ងៃទី១៦ ខែកក្កដា ខាងមុខនេះ។



Meeting with KC PTMT



Meeting with BTB PTMT

## ការអនុវត្តការបង្រៀនសាកល្បង គ្រូបង្គោលវគ្គ៣ (TOT3) សម្រាប់គ្រូបណ្ដុះបណ្ដាល INSET នាពេលអនាគត

ការបណ្ដុះបណ្ដាលគ្រូបង្គោលវគ្គ៣ (TOT3) សម្រាប់អ្នកបណ្ដុះបណ្ដាល INSET នាពេលអនាគតនៅខេត្តបាត់ដំបង និងខេត្តកំពង់ចាម ត្រូវបានបញ្ចប់ដោយជោគជ័យក្នុងខែឧសភា ឆ្នាំ២០២៥។ បន្ទាប់មក វគ្គបង្រៀនសាកល្បងសម្រាប់សិក្ខាកាមវគ្គTOT3 ត្រូវបានរៀបចំឡើងនៅខេត្តបាត់ដំបង ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី ១៣ ខែមិថុនា និងនៅខេត្តកំពង់ចាម ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា។

ក្នុងវគ្គការបង្រៀនសាកល្បង សិក្ខាកាមនីមួយៗត្រូវបានផ្ដល់មេរៀនមួយក្នុងវគ្គនីមួយៗ និងបានធ្វើបទបង្ហាញនៅចំពោះមុខគ្រូវាយតម្លៃ។ គ្រូវាយតម្លៃទាំងនេះ បានសង្កេតមើលវគ្គ និងវាយតម្លៃការអនុវត្តរបស់សិក្ខាកាមដោយប្រើសន្លឹកវាយតម្លៃដែលបង្កើតឡើងដោយគម្រោង និង TMT ថ្នាក់ជាតិ។ គ្រូបណ្ដុះបណ្ដាលត្រូវបានវាយតម្លៃលើទិដ្ឋភាពដូចជាការធ្វើផែនការមេរៀន ជំនាញទំនាក់ទំនង ការប្រើប្រាស់សម្ភារៈបង្រៀន និងបច្ចេកទេសសម្របសម្រួល។ មតិស្ថាបនាត្រូវបានផ្ដល់ជូនជាលក្ខណៈបុគ្គល ដើម្បីគាំទ្រដល់ការកែលម្អជាបន្តបន្ទាប់នៃជំនាញបង្រៀនរបស់ពួកគេ។

ការបង្រៀនសាកល្បងនេះមិនត្រឹមតែជាឱកាសមួយដើម្បីវាយតម្លៃការត្រៀមខ្លួនរបស់គ្រូបណ្ដុះបណ្ដាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរួមចំណែកក្នុងការជំរុញការរៀនសូត្រទៅវិញទៅមកក្នុងចំណោមគ្រូបណ្ដុះបណ្ដាលផងដែរ។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃ គ្រូបណ្ដុះបណ្ដាលដែលមានសមត្ថភាព នឹងត្រូវបានតែងតាំងជាផ្លូវការជាគ្រូបង្គោលតាមខេត្ត ហើយរំពឹងថានឹងដើរតួនាំមុខគេក្នុងការអនុវត្ត INSET នាពេលខាងមុខនៅក្នុងខេត្តទាំងពីរ។

គម្រោងសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះតួអង្គសំខាន់ៗទាំងអស់ដែលពាក់ព័ន្ធ ជាពិសេស HRDD, TMT, គ្រូបង្គោល, PHD, RTC, និង PRH សម្រាប់ការណែនាំដ៏មានតម្លៃរបស់ពួកគេ និងការសហការគ្នាដ៏រឹងមាំពេញមួយដំណើរការ។

របាយការណ៍ដ៏ទូលំទូលាយដែលសង្ខេបអំពីដំណើរការអនុវត្ត និងលទ្ធផលនៃការបណ្ដុះបណ្ដាលគ្រូបង្គោលវគ្គ៣ TOT3 នឹងត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងបង្ហាញនៅក្នុងកិច្ចប្រជុំ JCC លើកទី៦។







Demo Sessions in BTB&KC

## សកម្មភាពនាពេលខាងមុខក្នុងខែកក្កដា

- ថ្ងៃទី៣០ ខែមិថុនា ដល់ថ្ងៃទី៧ ខែកក្កដា៖ ធ្វើការវាយតម្លៃលើក្រោយការបណ្ដុះបណ្ដាលតាមប្រព័ន្ធអនឡាញ
- ថ្ងៃទី៧៖ កិច្ចប្រជុំប្រចាំខែជាមួយ JICA HQ/Cambodia Office
- ថ្ងៃទី១៦៖ កិច្ចប្រជុំ JCC លើកទី៦


## CONTACT INFORMATION

Scan here to find out more about us:

JICA's FB Page

Project's Homepage

**Email**: info@jicastrings.com

**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2,
Tuol Kork District, Phnom Penh

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh